ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ១៥៣០៦ អពដ

# សេចក្តីបំភ្លឺ

ក្រោយពីមានការបំភ្លឺជាច្រើនលើកច្រើនសា និងមានការជួបពិភាក្សាដោយផ្ទាល់រវាងអគ្គនាយកដ្ឋានពន្ធដារ និងតំណាងសារព័ត៌មាន The Cambodia Daily នាពេលថ្មីៗនេះ អគ្គនាយកដ្ឋានពន្ធដារពិនិត្យឃើញថា សារព័ត៌មានមួយនេះនៅតែមិនព្រមទទួលយកការពិតដែលថាខ្លួនមិនបានបំពេញកាតព្វកិច្ចសារពើពន្ធបានត្រឹមត្រូវ ហើយនៅតែព្យាយាមទាញភ្ជាប់ការមិនបំពេញកាតព្វកិច្ចពន្ធដារ ថាជាចេតនានយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប៉ុនប៉ងបិទកាសែតរបស់ខ្លួនទៅវិញ។ ជាក់ស្តែង នៅព្រឹកថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៧ នេះទៀត វិទ្យុអាស៊ីសេរីបានផ្សាយថាម្ចាស់កាសែត **The Cambodia Daily** បានចោទប្រកាន់ថា “**រដ្ឋាភិបាលកម្ពុជា កំពុងវាយប្រហារមកលើសេរីភាពសារព័ត៌មាន តាមរយៈការចង់បិទស្ថាប័នរបស់អ្នកស្រី ដោយក្លែងអធិករណ៍ទៅជារឿងមិនបង់ពន្ធវិញ**”។

អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបជូនសាធារណជន ក៏ដូចជាម្ចាស់សារព័ត៌មាន **The Cambodia Daily** ជ្រាបជាថ្មីម្តងទៀតថា អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងពង្រឹងការអនុវត្តច្បាប់ចំពោះរាល់អ្នកជាប់ពន្ធគ្រប់មជ្ឈដ្ឋាន ក្នុងគោលដៅគ្រប់គ្រងប្រមូលពន្ធប្រកបដោយប្រសិទ្ធភាព តម្លាភាព និងសមភាព និងបង្កើតនូវបរិយាកាសប្រកួតប្រជែងដោយស្មើភាពគ្នាក្នុងចំណោមអ្នកជាប់ពន្ធទាំងអស់។ ព្រមជាមួយនោះ ក៏បានរកឃើញថា កាសែត The Cambodia Daily ដែលបាននិងកំពុងដំណើរការអាជីវកម្ម រហូតមក មិនបានគោរពកាតព្វកិច្ចស្របតាមបទប្បញ្ញត្តិច្បាប់ស្តីពីពន្ធដារ និងបានប្រព្រឹត្តអំពើគេចវេះពន្ធរាប់ឆ្នាំ ដោយមិនប្រកាសបង់ពន្ធសូម្បីតែមួយរៀលណាសោះ។ មិនតែប៉ុណ្ណោះ ថែមទាំងប្រមូលអាករលើតម្លៃបន្ថែម ដែលជាថវិកាត្រូវបង់ជូនរដ្ឋដោយអ្នកប្រើប្រាស់ យកទៅដាក់ហោប៉ៅផ្ទាល់ខ្លួន ហើយចោទប្រកាន់មកលើរាជរដ្ឋាភិបាលខុសពីការពិតទៅវិញ។ តើករណីនេះគឺជាបញ្ហានយោបាយដែលរាជរដ្ឋាភិបាលគំរាមទៅលើសេរីភាពសារព័ត៌មាន ឬយ៉ាងណា? តើសារព័ត៌មានដទៃទៀតដែលបានប្រកាសបង់ពន្ធត្រឹមត្រូវមានអារម្មណ៍យ៉ាងណាដែរ នៅពេលដែលគេឃើញកាសែត The Cambodia Daily មិនប្រកាសបង់ពន្ធបែបនេះ? តើនេះឬ ជាការប្រកួតប្រជែងស្មើភាពគ្នាដែលមជ្ឈដ្ឋានអ្នកជាប់ពន្ធគ្រប់រូបប្រាថ្នាចង់បាន ឬជាបញ្ហានយោបាយ ដើម្បីប៉ុនប៉ងបិទកាសែតមួយនេះ?

អគ្គនាយកដ្ឋានពន្ធដារសូមបញ្ជាក់បន្ថែមជាថ្មីម្តងទៀតថា ប្រសិនបើកាសែតនេះនៅតែមិនព្រមបង់ពន្ធ អគ្គនាយកដ្ឋានពន្ធដារគ្មានជម្រើសអ្វីក្រៅពីការអនុវត្តច្បាប់នោះទេ ព្រោះថា អគ្គនាយកដ្ឋានពន្ធដារគឺជាអង្គភាពដែលមានក្រមសីលធម៌វិជ្ជាជីវៈ និងអនុវត្តច្បាប់យ៉ាងម៉ឺងម៉ាត់នូវបទប្បញ្ញត្តិច្បាប់ជាធរមាន។

អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបជូនផងដែរថា អគ្គនាយកដ្ឋានពន្ធដារបានចំណាយពេលវេលារាប់ឆ្នាំ ក្នុងការស៊ើបអង្កេតប្រមូលផ្តុំព័ត៌មានពាក់ព័ន្ធនឹងកាសែត The Cambodia Daily សម្រាប់ធ្វើជាមូលដ្ឋានក្នុងការកំណត់ពន្ធឡើងវិញនេះ ហើយថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៧ គឺគ្រាន់តែជាកាលបរិច្ឆេទនៃការសម្រេចចេញលទ្ធផលនៃការកំណត់ពន្ធតែប៉ុណ្ណោះ។ យោងតាមការតវ៉ាចំនួនពីរដងរួចមកហើយ និងតាមរយៈការជួបពិភាក្សាដោយផ្ទាល់អំពីការកំណត់ពន្ធនេះកាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ វេលាម៉ោង ៩:៣០ព្រឹក រវាងអគ្គនាយកដ្ឋានពន្ធដារ ជាមួយលោក Douglas Eric Steele តំណាងក្រុមហ៊ុន BERNARD KRISHER JUMUSHO CO., LTD អគ្គនាយកដ្ឋានពន្ធដារបានបង្ហាញជូនតំណាងក្រុមហ៊ុនយ៉ាងជាក់ច្បាស់រួចហើយ ទាំងផ្នែកទិដ្ឋភាពច្បាប់ និងទាំងអង្គហេតុជាក់ស្តែងដែលជាមូលដ្ឋាននៃការកំណត់ពន្ធឡើងវិញនេះ ក៏ប៉ុន្តែតំណាងក្រុមហ៊ុនមិនបានផ្តល់នូវសក្ខីកម្មណាមួយដើម្បីដោះបន្ទុកលើការកំណត់ពន្ធឡើងវិញនោះទេ


អាគារកែងមហាវិថី សហព័ន្ធរុស្សី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

ដែលសូម្បីតែតំណាងរូបនោះខ្លួនឯងស្ទើរតែមិនមានពាក្យអ្វីត្រូវហាស្ដី ឬហាមាត់និយាយមិនរួចផងចំពោះទឡ្ហីករណ៍នៃការកំណត់ពន្ធឡើងវិញនេះ ប៉ុន្តែបែរជាខិតខំបង្វែរស្ថានការណ៍នៃការមិនគោរពការតព្វកិច្ចបង់ពន្ធរបស់ខ្លួនទៅជាបញ្ហានយោបាយ ហើយស្នើឱ្យរដ្ឋាភិបាលនៃប្រទេសផ្សេងទៀត ជួយអន្តរាគមន៍លើរឿងនេះទៅវិញ។

អគ្គនាយកដ្ឋានពន្ធដារសូមសហគមន៍អន្តរជាតិនានាជួយផ្ដល់មតិថា នៅក្នុងបណ្ដាប្រទេសជឿនលឿន ប្រទេសនីតិរដ្ឋ តើរដ្ឋបាលសារពើពន្ធនៃប្រទេសរបស់អស់លោកមានចំណាត់ការយ៉ាងណា ចំពោះការមិនគោរពកាតព្វកិច្ចបង់ពន្ធរបស់អ្នកជាប់ពន្ធ នៅពេលដែលអ្នកជាប់ពន្ធណាម្នាក់បានប្រព្រឹត្តល្មើសលើបទប្បញ្ញត្តិស្ដីពីពន្ធដារ? តើករណីមិនគោរពច្បាប់បែបនេះ ជាចេតនានយោបាយ ឬយ៉ាងណា? ប្រសិនបើសហគមន៍អន្តរជាតិណាមួយដែលមាននិន្នាការគាំទ្រកាសែត The Cambodia Daily ហើយមានបំណងចង់ដឹងច្បាស់បន្ថែមអំពីការកំណត់ពន្ធឡើងវិញនេះ អគ្គនាយកដ្ឋានពន្ធដារសូមស្វាគមន៍ និងធ្វើបទបង្ហាញជូនលម្អិតអំពីករណីនេះ។

ព្រមជាមួយនេះ អគ្គនាយកដ្ឋានពន្ធដារសូមអំពាវនាវចំពោះមជ្ឈដ្ឋានជាតិ និងអន្តរជាតិ មេត្តាកុំយល់ច្រឡំអំពីការព្យាយាមបំភាន់សាធារណមតិ ដោយផ្សាភ្ជាប់ករណីនៃការមិនគោរពកាតព្វកិច្ចសារពើពន្ធ ជាមួយរឿងនយោបាយយ៉ាងដូច្នេះនោះទេ។

អាស្រ័យហេតុនេះ សូមសាធារណជន និងសារព័ត៌មាននានា មេត្តាជ្រាបជាព័ត៌មាន ព្រមទាំងស្វែងយល់ឱ្យបានច្បាស់លាស់អំពីច្បាប់និងបទប្បញ្ញត្តិនានាស្ដីពីពន្ធដារ។

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៧

**អគ្គនាយកដ្ឋានពន្ធដារ**